13/5

កា៨ 23/10/23

សំណុំរឿង 109 / 27-03-2023

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**
**សភាព្រហ្មទណ្ឌ**
សំណុំរឿងលេខៈ ៣១៤
ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២២
**សាលដីកា**
**លេខៈ ១២** ព្រ.ទ ក្រIII ( ទ.ណ )
ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

បានបង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦/០៧/២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ នាព្រឹកថ្ងៃពុធ ១៤កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ ដែលមានសមាសភាពដូចខាងក្រោម៖

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សា
ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា
ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted] ក្រឡាបញ្ជី

**<u>ជនជាប់ចោទ៖</u>**

-ឈ្មោះ [redacted] **គង់** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ទីលំនៅមុនពេលឃុំខ្លួននៅភូមិ [redacted] មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី២ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ ទោសពីមុន គ្មាន ។ **(អ្នកប្តឹងឧទ្ធរណ៍)**

**-ដីកាបង្គាប់ឲ្យចាប់ និងឃុំខ្លួនលេខៈ៧៧៨ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២។**

ជាប់ចោទពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**<u>ទណ្ឌិត៖</u>**

-ឈ្មោះ [redacted] **សុខខួច** ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ទីលំនៅមុនពេលឃុំខ្លួនភូមិ [redacted] មុខរបរធ្វើស្រែចំការ កាន់សាសនា



ស្កេនជាមួយ CamScanner

ព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៥។ ស្ថានភាពគ្រួសារនៅលីវ ឪពុកឈ្មោះ [redacted](ស្លាប់) ម្តាយឈ្មោះ [redacted](រស់) ទោសពីមុនគ្មាន។

**-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ០៦ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០២២។**

ត្រូវផ្តន្ទាទោសពីបទៈ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ១. អំពីអង្គហេតុ

កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខខួច ភេទប្រុស អាយុ៤១ឆ្នាំ នៅចំណុចទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងបានឆែកឆេរឃើញថ្នាំញៀនចំនួន ០១កញ្ចប់។ ជនជាប់ចោទសារភាពថាថ្នាំញៀនខាងលើខ្លួនទិញពីឈ្មោះ [redacted]គង់ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ។

## ២. អំពីសេចក្តីសម្រេចរបស់សាលាដំបូង

**-បានឃើញៈ** សាលក្រមព្រហ្មទណ្ឌលេខៈ៣២០ "ធ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ បានចេញសេចក្តីសម្រេចដូចតទៅៈ

១.ផ្តន្ទាទោសលើឈ្មោះ ៖

ក. ឈ្មោះ[redacted]សុខខួច ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិខាងលើ)

ដាក់ពន្ធនាគារកំណត់ចំនួន ២(ពីរ)ឆ្នាំ និង៦(ប្រាំមួយ)ខែ ពីបទៈ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ.ឈ្មោះ[redacted]**គង់** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ៣(បី)ឆ្នាំ ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.បញ្ឈប់អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរលេខៈ៤០ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ លើជនជាប់ចោទឈ្មោះ[redacted]គង់ ភេទប្រុស អាយុ២៨ឆ្នាំ។

-បង្គាប់ឱ្យចាប់ និងឃុំខ្លួន ឈ្មោះ [redacted]**គង់** ភេទប្រុស អាយុ២៨ឆ្នាំ (មានសាវតាជាតិដូចខាងលើ) តាមអំណាចសាលក្រមព្រហ្មទណ្ឌ ស្របតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.វត្ថុចាប់យកមានៈ ថ្នាំញៀនដែលដាក់ក្នុងស្រោមសំបុត្រពណ៌គគីរ ជាប្រភេទថ្នាំញៀន មេតំហ្វេតាមីន មានទម្ងន់ ០,២៦ (សូន្យក្បៀសម្ភៃប្រាំមួយ) ក្រាម ត្រូវសម្រេចបំផ្លាញ។

៤.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]**សុខខួច** និងកំបាំងមុខជនជាប់ចោទឈ្មោះ[redacted]**គង់**។

**- បានឃើញៈ** សាលក្រមព្រហ្មទណ្ឌលេខៈ៤៩១ "ធ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ បានចេញសេចក្តីសម្រេចដូចតទៅៈ

១.ទទួលពាក្យបណ្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខៈ៣២០"ធ"ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៣២០ "ធ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាបានការទាំងមូលដដែល។

៣.សាលក្រមនេះ បានជំនុំជម្រះនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]គង់។



ស្កេនជាមួយ CamScanner

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**-បានឃើញ** សេចក្តីបណ្តឹងឧទ្ធរណ៍លេខ: ៨៧ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] គង់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ៤៩១(ធ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ត្រង់ចំណុចសម្រេចទាំងមូល។

**-បានឃើញ** របាយការណ៍ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ត្បូងឃ្មុំ។

**-បានឃើញ** សេចក្តីសន្និដ្ឋានចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

## ៣.អំពីកិច្ចពិភាក្សាដេញដោល

- ចៅក្រមរបាយការណ៍ អានរបាយការណ៍រឿង។

- តំណាងមហាអយ្យការធ្វើការកត់សំគាល់។

-ទណ្ឌិតឈ្មោះ [redacted] សុខខួច នាពេលសវនាការបានឆ្លើយថា៖ ខ្លួនធ្លាប់ស្គាល់ឈ្មោះ បាន គង់ ពីមុនមក ជាង១០ឆ្នាំមុន។ ឈ្មោះ [redacted] គង់ មិនបានស៊ីឈ្នួលគេទេ គ្រាន់តែទៅស្នាក់នៅផ្ទះខ្លួនកន្លះខែ ទៅ១ខែប៉ុណ្ណោះ។ ឈ្មោះ គង់ ដែលបានលក់ថ្នាំញៀនឲ្យខ្លួនគឺមានរូបរាង មាឌធំ ខ្ពស់ ខ្មៅស្រអែម សក់វែងចំហៀង ខ្ពស់ប្រហែល១,៧០ជាងមិនមែនឈ្មោះ [redacted] គង់ ដែលនៅក្នុងសវនាការជាមួយខ្លួននេះទេ ហើយក៏អត់ដែលពាក់ព័ន្ធរឿងថ្នាំញៀនជាខ្លួនទេ។ ចំពោះចម្លើយនៅប៉ូលីសថាខ្លួនទិញពីឈ្មោះ [redacted] គង់ គឺប៉ូលីសជាអ្នកថា រីឯខ្លួនថាស្គាល់តែឈ្មោះ គង់ អត់ស្គាល់ត្រកូល។ ខ្លួនមិនដឹងថាឈ្មោះ [redacted] គង់ យកប្រពន្ធនៅណាទេ ហើយក៏មិនដែលបានឆ្លើយថាគាត់មានប្រពន្ធនៅណាទេ។ មិនដែលដឹងថាឈ្មោះ [redacted] គង់ នេះធ្លាប់ជាប់ពន្ធនាគារឬអត់ទេ។ ពេលដែលប៉ូលីសសួរ មិនបានមានរូបថតឈ្មោះ [redacted] គង់ មកបង្ហាញទេ។ ខ្លួនពុំធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] គង់ ដែលនៅក្នុងសវនាការជាមួយខ្លួននេះទេ គឺធ្លាប់តែទៅទិញថ្នាំញៀនជាមួយឈ្មោះ គង់ ម្នាក់ទៀត ហើយឈ្មោះ គង់ ដែលខ្លួនធ្លាប់ទិញថ្នាំញៀននៅកន្លែងគេលេងអាប៉ោងនោះ គឺខ្លួនមិនដឹងថាគាត់នៅម្តុំណានោះទេ ព្រោះខ្លួនពុំស្គាល់ស្រុកកំណើតនោះទេ។ ខ្លួនទិញថ្នាំញៀនពីឈ្មោះ គង់ នៅភូមិទួលមានជ័យ ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ តែមកលក់នៅកន្លែងលេងអាប៉ោង ហើយខ្លួនពុំដែលស្គាល់ត្រកូលឈ្មោះ គង់ នោះទេ។

-ជនជាប់ចោទឈ្មោះ [redacted] **គង់** បានឆ្លើយថា៖ បានជាខ្លួនប្តឹងឧទ្ធរណ៍ដោយសារខ្លួនមិនសុខចិត្ត នឹងទោសដោយសារខ្លួនមិនបានប្រព្រឹត្តនោះទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] សុខខួច ដែរ ព្រោះពីមុនមកធ្លាប់ទៅនៅផ្ទះគាត់តាំងពីតូចមកម្ល៉េះ។ ខ្លួនមិនទទួលស្គាល់ថាបានលក់ថ្នាំញៀនឲ្យឈ្មោះ [redacted] សុខខួច ទេ ហើយធ្លាប់ស្គាល់ឈ្មោះ [redacted] សុខខួច តាំងពីអាយុ១០ឆ្នាំ តិចតួច ខ្លួនមកលេងផ្ទះឈ្មោះ គីម សុខខួច ដោយពេលនោះខ្លួនចេញពីវត្តមក ហើយស្នាក់នៅផ្ទះប្រហែលកន្លះខែ អត់បានស៊ីឈ្នួលគេទេ។ ខ្លួនជាបងប្អូនធម៌និងឈ្មោះ [redacted] សុខខួច។ ខ្លួនធ្លាប់ជាប់ពន្ធនាគារនៅឆ្នាំ២០១៨ និងចេញមកវិញនៅឆ្នាំ២០១៩ ពីបទ: ជួញដូរគ្រឿងញៀនផងដែរ។ កាលអំឡុងខែធ្នូ ឆ្នាំ២០២១ ខ្លួនធ្លាប់បានជួបឈ្មោះ [redacted] សុខខួច នៅកន្លែងចាក់អាប៉ោងម្តងដែរ ប៉ុន្តែខ្លួនពុំបានលក់ថ្នាំញៀនឱ្យឈ្មោះ [redacted] សុខខួច នោះទេ។ ខ្លួនពុំដែលប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ [redacted] សុខខួច នោះទេ គឺខ្លួនពុំបាននិយាយគ្នានោះទេ ព្រោះពេលនោះឈ្មោះ [redacted] សុខខួច កំពុងរវល់លេងអាប៉ោង។ ក្រោយពេលដែលខ្លួនចេញពីពន្ធនាគារ គឺខ្លួនពុំដែលជួញដូរ ឬប្រើប្រាស់គ្រឿងញៀន នោះទេ។ ខ្លួនធ្លាប់ជួបឈ្មោះ [redacted] សុខខួច បានម្តងក្រោយពេលចេញពីគុក នៅកន្លែងគេលេងអាប៉ោង។ ខ្លួនជាអ្នកលក់ត្រីនៅស្រែសៀម ហើយពេលខ្លួនរៀបការ គឺពុំបានប្រាប់គាត់នោះទេ។

-តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការតំណាងអយ្យការយល់ឃើញថា ជនជាប់ចោទថាមិនបានលក់ថ្នាំញៀនទៅឲ្យឈ្មោះ [redacted] សុខខួច ឡើយ ហើយឈ្មោះ [redacted] សុខខួច ក៏បានឆ្លើយថាថ្នាំញៀនមិនបានទិញពីឈ្មោះ គង់ ទេ។ ជនជាប់ចោទថាខ្លួនជាប្អូនជីដូនមួយនឹងឈ្មោះ [redacted] សុខខួច ដូច្នេះគឺមានការស្គាល់ច្បាស់។ មួយវិញទៀត ពុំមានភស្តុតាង សាក្សីណាមួយដោះបន្ទុក ទៅលើចម្លើយរបស់ជនជាប់ចោទនិងទណ្ឌិតបានទេ។ ហេតុដូច្នេះតំណាងមហាអយ្យការ ស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យ និងពិចារណា និងសម្រេចតាមច្បាប់។

-ជនជាប់ចោទឈ្មោះ [redacted] **គង់** បានធ្វើការសំណូមពរចុងក្រោយថា: សូមជួយបន្ធូរបន្ថយទោស ព្រោះខ្លួនមិនបានប្រព្រឹត្តិដូចការចោទប្រកាន់ឡើយ។



ស្កេនជាមួយ CamScanner

- ក្រោយពីបានចម្លើយរបស់ទណ្ឌិត
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## ៤.សំអាងហេតុ

៤.១-បណ្តឹងឧទ្ធរណ៍លេខៈ ៨៧ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] គង់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ៤៩១ "ធ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ត្រង់សេចក្តី **សម្រេចទាំងមូល** ធ្វើឡើងតាមកំណត់ច្បាប់ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ៣៧៥ មាត្រា៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨៧ មាត្រា ៣៦៨ មាត្រា៣៧២ មាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជនជាប់ចោទអាចប្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងផលប្រយោជន៍របស់ខ្លួនប៉ុណ្ណោះ។

៤.២-ឆ្លងតាមការសាកសួរដេញដោលនៃសាលាឧទ្ធរណ៍ ពិចារណាឃើញអង្គហេតុថាៈ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២១ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខខួច ភេទប្រុស អាយុ៤១ឆ្នាំ នៅចំណុចទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងបានឆែកឆេររកឃើញថ្នាំញៀនចំនួន ០១កញ្ចប់ ។ ជនជាប់ចោទសារភាពថាថ្នាំញៀនខាងលើខ្លួនទិញពីឈ្មោះ [redacted] គង់។

-ផ្អែកតាមចម្លើយរបស់ទណ្ឌិតឈ្មោះ [redacted] សុខខួច បានឆ្លើយច្បាស់នៅមន្រ្តីនគរបាលយុត្តិធម៌ ក៏ដូចនៅតំណាងអយ្យការ ចៅក្រមស៊ើបសួរ និងសាលាដំបូងខេត្តត្បូងឃ្មុំ(នាពេលសវនាការលើកទី១) ថាជនជាប់ចោទឈ្មោះ [redacted] គង់ ពិតជាបានលក់ថ្នាំញៀនឲ្យខ្លួន។

-នៅពេលសវនាការលើកទី២ (បណ្តឹងទាស់របស់ជនជាប់ចោទឈ្មោះ [redacted] គង់) ទណ្ឌិតឈ្មោះ [redacted] សុខខួច បានឆ្លើយថាខ្លួនមិនបានស្គាល់ជនជាប់ចោទឈ្មោះ [redacted] គង់ ទេ។ រីឯនៅសវនាការនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំវិញ ទណ្ឌិតនេះបែរជាឆ្លើយសារភាពថា ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] គង់ ពីមុនមក កាលពីជាង១០ឆ្នាំមុន ដោយឈ្មោះ [redacted] គង់ បានស្នាក់នៅផ្ទះខ្លួនកន្លះខែ ទៅ១ខែ។ ខ្លួនពុំធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] គង់ ដែលនៅសវនាការនេះជាមួយខ្លួនទេ គឺធ្លាប់តែទៅទិញថ្នាំញៀនជាមួយឈ្មោះ គង់ ម្នាក់ទៀត។

-តាមចម្លើយនេះ មិនអាចឲ្យតុលាការជឿជាក់បានទេ ព្រោះគ្រាន់តែជាចម្លើយចង់ដោះបន្ទុកឲ្យឈ្មោះ [redacted] គង់ តែប៉ុណ្ណោះ។ មួយវិញទៀតមានការស៊ីសង្វាក់គ្នា ចំពោះចម្លើយថាបានទិញថ្នាំញៀននៅកន្លែងលេងអាប៉ោង ហើយឈ្មោះ បាន គង់ ក៏បានឆ្លើយថាខ្លួនបានទៅឃើញឈ្មោះ [redacted] សុខខួច នៅកន្លែងលេងអាប៉ោងនោះមែន។ ហេតុដូច្នេះក្រុមប្រឹក្សាជំនុំជម្រះជឿជាក់ថា ជនជាប់ចោទឈ្មោះ [redacted] គង់ ពិតជាបានលក់ថ្នាំញៀនឲ្យឈ្មោះ [redacted] សុខខួច ពិតប្រាកដមែន។

៤.៣-ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ ពិចារណាឃើញថាៈ ថ្នាំញៀនដែលបានដកហូតពីឈ្មោះ [redacted] សុខខួច ដែលទិញពីឈ្មោះ [redacted] គង់ មានទម្ងន់ត្រឹមតែ០,២៦(សូន្យក្បៀសម្ភៃប្រាំមួយ) ក្រាម តែប៉ុណ្ណោះ។ ដូច្នេះការសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] គង់ កំណត់រយៈពេល ០៣(បី)ឆ្នាំ មានកម្រិតខ្ពស់ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា ពីការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] គង់ ឡើងវិញ។

៤.៤-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ក្រុមប្រឹក្សាជំនុំជម្រះបានពិចារណារួចហើយ ដោយមានសំអាងហេតុដូចខាងលើ។

៤.៥-សំណូមពរចុងក្រោយរបស់ជនជាប់ចោទ ក្រុមប្រឹក្សាជំនុំជម្រះបានពិចារណា ដោយមានសំអាងហេតុដូចខាងលើខាងលើ។



ស្កេនជាមួយ CamScanner

## ៥.ហេតុដូច្នេះ សម្រេច

**៥.១**-ទទួលបណ្តឹងឧទ្ធរណ៍លេខៈ ៨៧ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] **គង់** ទុកត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ខ្លះ។

**៥.២**-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៤៩១"ធ"ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាបានការដដែល លើកលែងចំណុចទី២ នៃសេចក្តីសម្រេច និងចំណុចទី១(ខ)នៃសេចក្តីសម្រេចរបស់សាលក្រមព្រហ្មទណ្ឌលេខៈ ៣២០ "ធ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ត្រូវបានកែប្រែ និងសម្រេចសារជាថ្មីដូចខាងក្រោមៈ

-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **គង់** ភេទប្រុស អាយុ២៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៥.៣**-សាលដីកានេះប្រកាសជាសាធារណៈ នៅព្រឹកថ្ងៃអង្គារ៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **គង់**។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |



ស្កេនជាមួយ CamScanner